ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តពោធិ៍សាត់
គណៈកម្មាធិការលទ្ធកម្ម(គ.ល)
លេខ : ..០៤.............អល.ពស

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការងារជួសជុល ថែទាំផ្លូវលេខ ២០៩ ដោយចាក់កៅស៊ូ DBST
## ប្រវែង ៦០០ម៉ែត្រ ទទឹង ១៣.៨ម៉ែត្រ ពីកែងផ្លូវលេខ ១០៦ ដល់កែងផ្លូវលេខ ១០៩
## ខាងមុខមជ្ឈមណ្ឌលអភិវឌ្ឍន៍ប៊ុនរ៉ានី ហ៊ុនសែន ជូនសាលាខេត្តពោធិ៍សាត់

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

សាលាខេត្តពោធិ៍សាត់ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ៖ សាលាខេត្តពោធិ៍សាត់ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារជួសជុល ថែទាំផ្លូវលេខ២០៩ ដោយចាក់កៅស៊ូDBST ប្រវែង៦០០ម៉ែត្រ ទទឹង១៣.៨ម៉ែត្រ ពីកែងផ្លូវលេខ១០៦ ដល់កែងផ្លូវលេខ១០៩ ខាងមុខមជ្ឈមណ្ឌលអភិវឌ្ឍន៍ប៊ុនរ៉ានី ហ៊ុនសែន ជូនសាលាខេត្តពោធិ៍សាត់ ។

បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តពោធិ៍សាត់ ដែលមានអាសយដ្ឋាននៅសាលាខេត្តពោធិ៍សាត់ ចាប់ពីថ្ងៃទី..២១.....ខែ..មេសា.. ឆ្នាំ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១២ ៩៧ ៦៥ ៤៦ ) ។ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី..២៣...ខែ..ឧសភា...ឆ្នាំ២០១៦វេលាម៉ោង ..០៩:៣០.......។ ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ..០៩:៣០........... ថ្ងៃទី..២៣.....ខែ..ឧសភា...ឆ្នាំ ២០១៦ ។ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅពោធិ៍សាត់ថ្ងៃទី ..១៩...... ខែ ..មេសា.. ឆ្នាំ ២០១៦
ប្រធានគណៈកម្មាធិការលទ្ធកម្ម (គ.ល)

ម៉ៅ ធនិន

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ